ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ
នៅកម្ពុជាឆ្នាំ ២០២២-២០៣៥

ខែឆ្នូ ឆ្នាំ២០២២

មាតិកា

អារម្ភកថា i

ខ្លឹមសារសង្ខេប ២

សេចក្តីផ្តើម ៤

អភិក្រមប្រើប្រាស់សម្រាប់រៀបចំផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ ៨

ទិដ្ឋភាពទូទៅនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ ១០

គោលបំណងគន្លឹះ និងសូចនាករអនុវត្ត ១១

តួនាទីរបស់តួអង្គពាក់ព័ន្ធសំខាន់ៗ ១៣

ការត្រួតពិនិត្យ ១៩

សកម្មភាពតម្រង់ទិស និងពេលវេលានៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ២០

ខ្លឹមសារសង្ខេប

នៅក្រោមបាវចនា "**ជាតិ សាសនា ព្រះមហាក្សត្រ**" និងតាមការចង្អុលបង្ហាញក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងបន្តអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិរបស់ខ្លួន ដើម្បីសម្រេចឱ្យបានតាមចក្ខុវិស័យឆ្នាំ២០៣០ និង២០៥០។ ទន្ទឹមនឹងការប្រែប្រួលដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាបដិវត្តន៍ឧស្សាហកម្ម៤.០ ក៏ដូចជាក្នុងបរិបទនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាក៏បានបង្ហាញការប្តេជ្ញាចិត្តយ៉ាងពេញទំហឹងចំពោះការអភិវឌ្ឍធនធានមនុស្ស តាមរយៈកិច្ចខិតខំពង្រឹងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) និងបានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការរៀបចំផែនទីបង្ហាញផ្លូវស្តីពី "ការអភិវឌ្ឍជំនាញនៅកម្ពុជាឆ្នាំ២០២២-២០៣៥" (ហៅកាត់ថាផែនទីបង្ហាញផ្លូវ)។ ផែនទីបង្ហាញផ្លូវនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជួយចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយការប្រឈមនានា និងផ្តល់ឱកាសដល់ឧស្សាហកម្មកម្ពុជាឱ្យទទួលបាននូវកម្លាំងពលកម្មប្រកបដោយជំនាញ និងនវានុវត្តន៍ ដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជាស្របទៅតាមគោលនយោបាយ និងយុទ្ធសាស្ត្រចម្បងៗរបស់រាជរដ្ឋាភិបាល រួមមាន៖ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ និងផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០ជាដើម។ បន្ថែមពីនេះ ក្នុងគោលដៅរក្សាភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលវែង ក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព ផែនទីបង្ហាញផ្លូវនេះ ក៏នឹងចូលរួមចំណែកក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០ ចំនួន ៧ គោលដៅ រួមមាន៖ គោលដៅទី៤ ទី៥ ទី៧ ទី៨ ទី៩ ទី១៣ និងគោលដៅទី១៧។

ជារួម ផែនទីបង្ហាញផ្លូវនេះមានគោលបំណងចំនួន២៦ និងសូចនាករអនុវត្តចំនួន២៧ ដែលមានភាពប្រទាក់ក្រឡាគ្នា និងគាំទ្រឱ្យសរសរស្តម្ភយុទ្ធសាស្ត្រចម្បងៗ ចំនួន ៥ ដូចខាងក្រោម៖

១. ការពង្រឹងគុណភាព និងស្តង់ដា៖ សំដៅពង្រឹងគុណភាព និងស្តង់ដា TVET នៃកម្លាំងពលកម្មជំនាញរបស់កម្ពុជា អោយត្រៀមខ្លួនរួចរាល់សម្រាប់ឧស្សាហកម្ម និងតម្រូវការទីផ្សារការងារ ឆ្ពោះទៅ

ការអនុវត្តពេញលេញនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងការលើកកម្ពស់ការកសាងហេដ្ឋារចនាសម្ព័ន្ធ TVET កញ្ចប់បណ្តុះបណ្តាលជំនាញ និងការកសាងសមត្ថភាពគ្រូបច្ចេកទេស ជាដើម (មានគោលបំណងចំនួន៧ និងសូចនាករអនុវត្តន៍ចំនួន៨)។

២. ការលើកកម្ពស់កិត្តិនាម និងការផ្សព្វផ្សាយ៖ សំដៅកសាងកិត្តិនាម និងអត្តសញ្ញាណដោយប្រើយុទ្ធសាស្ត្រផ្សព្វផ្សាយ និងកម្មវិធីដែលមិនទុកនរណាម្នាក់ចោល។ ក្នុងនោះ ក៏សំដៅទៅលើការបង្កើនការចូលរួម និងការយល់ដឹងពីការបណ្តុះបណ្តាលជំនាញ ការផ្តោតលើការកសាងកិត្តិនាម ការប្រឹក្សាយោបល់ និងការតស៊ូមតិ ការកែលម្អលទ្ធភាពចូលរៀនរបស់ក្រុមងាយរងគ្រោះ ការលើកកម្ពស់សហគ្រិនភាព និងការផ្តល់ឱកាសការហ្វឹកហ្វឺនកូនជាងផងដែរ (មានគោលបំណងចំនួន៥ និងសូចនាករអនុវត្តន៍ចំនួន៦)។

៣. TVET ដែលឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម៖ សំដៅដល់ការពង្រីកតួនាទី ភារកិច្ច និងការចូលរួម របស់វិស័យឯកជននៅក្នុងការអភិវឌ្ឍជំនាញ ពង្រឹង និងពង្រីកបណ្តាញរវាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧស្សាហកម្ម លើកកម្ពស់ការរៀបចំជំនាញឡើងវិញ (Reskilling) និងការបង្កើនជំនាញ (Upskilling) និងបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យបន្ថែមទៀត (មានគោលបំណងចំនួន៤ និងសូចនាករអនុវត្តន៍ចំនួន៥) ។

៤. អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ៖ សំដៅលើការបង្កើនប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ/យន្តការនៅគ្រឹះស្ថាន TVET ការអនុវត្តចាប់តាំងពីការរៀបចំដល់ការអនុវត្តកម្មវិធីកែទម្រង់ ដើម្បីកែលម្អការគ្រប់គ្រងថ្នាក់ជាតិ បង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព និងការបង្កើត ផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ TVET (ក្រុមប្រឹក្សាយោបល់សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតួអង្គពាក់ព័ន្ធផ្សេងទៀតសម្រាប់ TVET) (មានគោលបំណងចំនួន៦ និងសូចនាករអនុវត្តន៍ចំនួន៥)។

៥. ការផ្តល់ហិរញ្ញប្បទាន និងចីរភាព៖ សំដៅលើការលើកកម្ពស់ប្រសិទ្ធផល (ផលិតភាព) និងប្រសិទ្ធភាព(បច្ច័យ) នៃយន្តការផ្តល់ហិរញ្ញប្បទានដែលមានស្រាប់នៃមូលនិធិអភិវឌ្ឍន៍ជំនាញ ពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ដោយឆ្ពោះទៅរកការអនុវត្តផ្នែកលើលទ្ធផល និងស្វ័យភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញ បង្កើនការវិភាជន៍ថវិកាថ្នាក់ជាតិសម្រាប់ TVET /ការអភិវឌ្ឍជំនាញ បង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងមូលនិធិដែលមានស្រាប់ពីដៃគូ មានដូចជាអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ វិស័យឯកជន។ល។ (មានគោលបំណងចំនួន ៤ និងសូចនាករអនុវត្តចំនួន ៣)។

សេចក្តីផ្តើម

ឆ្លើយតបនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ចក្នុងតំបន់និងសកលលោក បច្ចេកវិទ្យាឈានមុខនៃបដិវត្តឧស្សាហកម្ម ៤.០ និងគម្លាតជំនាញ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនយ៉ាងមោះមុត ក្នុងការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) តាមរយៈការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានារួមមាន៖ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិ ស្តីពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ គោលនយោបាយជាតិស្តីពី មុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ គោលនយោបាយជាតិស្តីពី ការសិក្សាពេញមួយជីវិត ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ និងផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០។ លើសពីនេះទៀត កម្ពុជាមានគម្រោងជាច្រើនដែលបានផ្តល់មូលនិធិពីតួអង្គផ្តល់ជំនួយហើយបាន និងកំពុងអនុវត្តនៅក្នុងប្រទេសដើម្បីធ្វើបវិវត្តកម្ម ទំនើបកម្ម និងពង្រឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ នេះបង្ហាញថា ការអភិវឌ្ឍជំនាញពិតជាជាគន្លឹះអាទិភាពដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល វិស័យសង្គម និងអង្គការអន្តរជាតិ។

ផែនទីបង្ហាញផ្លូវនេះ ត្រូវបានធ្វើឡើងឱ្យស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០ និងគោលនយោបាយយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំផ្សេងៗរបស់កម្ពុជាដូចបានរៀបរាប់ខាងលើ។ គោលដៅអភិវឌ្ឍន៍គន្លឹះប្រកបដោយចីរភាព និងគោលដៅរងដែលស្របគ្នាជាមួយនឹងការអភិវឌ្ឍជំនាញ រួមមាន៖

ឈ្មោះគោលដៅ	គោលដៅរង
គោលដៅទី ៤ ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពនៃការសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប	• **ចំណុចដៅ ៤.៣** លទ្ធភាពទទួលបានស្មើគ្នានូវការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនិងឧត្តមសិក្សាប្រកបដោយគុណភាព • **ចំណុចដៅ ៤.៤** ត្រឹមឆ្នាំ២០៣០ បង្កើននិរន្តភាពចំនួនយុវជននិងមនុស្សពេញវ័យដែលមានជំនាញពាក់ព័ន្ធ រួមទាំងជំនាញបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ការងារសមរម្យ និងសហគ្រិនភាព • **ចំណុចដៅ ៤.៥** ត្រឹមឆ្នាំ២០៣០ លុបបំបាត់គម្លាតយេនឌ័រ នៅក្នុងវិស័យអប់រំនិងធានាការទទួលបានភាពស្មើគ្នាក្នុងការអប់រំគ្រប់កម្រិត និងនៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ក្រុមជនងាយរងគ្រោះ រួមទាំងក្រុមដែលបាត់បង់សមត្ថភាពពលកម្ម ប្រជាជន និងកុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ • **ចំណុចដៅ ៤.៧** ធានាថាអ្នកសិក្សាទាំងអស់ រួមទាំងអ្នកពាក់ព័ន្ធដទៃទៀតទទួលបានចំណេះដឹង និងជំនាញចាំបាច់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព • **ចំណុចដៅ ៤.គ** ត្រឹមឆ្នាំ ២០៣០ បង្កើនការផ្គត់ផ្គង់គ្រូបង្រៀនដែលមានគុណភាពឱ្យបានច្រើន តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសប្រទេសអភិវឌ្ឍន៍តិចតួច និងរដ្ឋកោះតូចៗដែលកំពុងអភិវឌ្ឍន៍
គោលដៅទី ៥៖ សម្រេចសមភាពយេនឌ័រនិងផ្តល់ភាពអង់អាចដល់ស្ត្រី និងកុមារីទាំងអស់	• **ចំណុចដៅ ៥.ក** ធ្វើកំណែទម្រង់ដើម្បីផ្តល់សិទ្ធិស្មើគ្នាដល់ស្ត្រីលើផ្នែកធនធានសេដ្ឋកិច្ច ក៏ដូចជាការទទួលបានកម្មសិទ្ធិ និងការគ្រប់គ្រងលើដីធ្លី និងទ្រព្យសម្បត្តិផ្សេងៗទៀត សេវាកម្មហិរញ្ញវត្ថុ ធនធានដែលជាមរតក និងធនធានធម្មជាតិ ស្របតាមច្បាប់ជាតិ

ឈ្មោះគោលដៅ	គោលដៅរង
	• **ចំណុចដៅ ៥.ខ** បង្កើនការប្រើប្រាស់បច្ចេកវិទ្យាដែលអាចប្រើបានជាពិសេសបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដើម្បីលើកកម្ពស់ការពង្រឹងភាពអង់អាចដល់ស្ត្រី
គោលដៅទី ៧៖ ធានាបានលទ្ធភាពប្រើប្រាស់ថាមពលដែលមានតម្លៃសមរម្យ អាចទុកចិត្តបាន និរន្តរភាព និងទំនើបកម្មសម្រាប់ទាំងអស់គ្នា	• **ចំណុចដៅ ៧.២** ត្រឹមឆ្នាំ ២០៣០ បន្តបង្កើនចំណែក នៃថាមពលកកើតឡើងវិញនៅក្នុងល្បាយថាមពលពិភពលោក • **ចំណុចដៅ ៧.៣** បង្កើនអត្រាប្រសិទ្ធភាពថាមពលសកលឱ្យបាន ២ដង ត្រឹមឆ្នាំ ២០៣០ • **ចំណុចដៅ ៧.ក** ត្រឹមឆ្នាំ ២០៣០ បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីសម្រួលដល់ការទទួលបានការស្រាវជ្រាវនិងបច្ចេកវិទ្យាថាមពលស្អាត រួមទាំងថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងបច្ចេកវិទ្យាឥន្ធនៈផូស៊ីលកម្រិតខ្ពស់និងស្អាត និងជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពល និងបច្ចេកវិទ្យាថាមពលស្អាត
គោលដៅទី ៨៖ កំណើនសេដ្ឋកិច្ច និងការងារពេញលេញ ប្រកបដោយផលិតភាព និងសមរម្យ	• **ចំណុចដៅ ៨.៥** ត្រឹមឆ្នាំ២០៣០ ទទួលបានការងារពេញលេញប្រកបដោយផលិតភាព និងសមរម្យសម្រាប់ស្ត្រីនិងបុរសទាំងអស់ រួមទាំងយុវជន និងជនពិការ ហើយទទួលបានការទូទាត់កម្រៃការងារស្មើគ្នានិងតម្លៃស្មើគ្នា • **ចំណុចដៅ ៨.៦** ត្រឹមឆ្នាំ២០៣០ កាត់បន្ថយយ៉ាងច្រើននូវសមាមាត្រយុវជនដែលមិនមានការងារធ្វើ មិនមានការអប់រំ ឬការបណ្តុះបណ្តាល
គោលដៅទី ៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបបរិយាប័ន្ន និងចីរភាព និងជំរុញនវានុវត្តន៍	• **ចំណុចដៅ ៩.៥** លើកម្ពស់ស្រាវជ្រាវវិទ្យាសាស្ត្រ បង្កើនសមត្ថភាពបច្ចេកវិទ្យារបស់វិស័យឧស្សាហកម្មនៅគ្រប់ប្រទេស ជាពិសេសបណ្តាប្រទេសកំពុងអភិវឌ្ឍ ត្រឹមឆ្នាំ២០៣០ លើកទឹកចិត្តនវានុវត្តន៍ និងការបង្កើនចំនួនបុគ្គលិកស្រាវជ្រាវនិងអភិវឌ្ឍន៍ឱ្យបានច្រើន

ឈ្មោះគោលដៅ	គោលដៅរង
	ក្នុងចំណោមប្រជាជន១លាននាក់ និងបង្កើនការចំណាយដល់ការស្រាវជ្រាវនិងការអភិវឌ្ឍផ្នែកសាធារណៈនិងឯកជន
គោលដៅទី ១៣៖ ចាត់វិធានការបន្ទាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ	• **ចំណុចដៅ ១៣.៣** លើកម្ពស់ការអប់រំ ការយល់ដឹង និងសមត្ថភាពមនុស្សនិងស្ថាប័ន ស្តីពីការបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុ ការបន្សាំ ការកាត់បន្ថយផលប៉ះពាល់ និងការផ្តល់នូវការក្រើនរំលឹកឱ្យប្រយ័ត្នជាមុន • **ចំណុចដៅ ១៣.ខ** លើកកម្ពស់យន្តការបង្កើនសមត្ថភាពសម្រាប់ការធ្វើផែនការ និងការគ្រប់គ្រងដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពដោយផ្តោតលើស្ត្រី យុវជន សហគមន៍ប្រជាជនក្នុងមូលដ្ឋាន និងសហគមន៍ងាយរងគ្រោះ
គោលដៅទី ១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើនភាពរស់រវើកនៃភាពភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព	• **ចំណុចដៅ ១៧.១** ពង្រឹងការកៀរគរធនធានក្នុងស្រុក តាមរយៈការគាំទ្រអន្តរជាតិដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់សមត្ថភាពក្នុងស្រុកសម្រាប់ប្រមូលពន្ធ និងចំណូលផ្សេងទៀត • **ចំណុចដៅ ១៧.១៧** លើកទឹកចិត្ត និងលើកកម្ពស់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពផ្នែកសាធារណៈ ផ្នែកសាធារណៈនិងផ្នែកឯកជនជាមួយនឹងសង្គមស៊ីវិល ដោយកសាងផ្អែកលើបទពិសោធន៍និងយុទ្ធសាស្ត្រផ្តល់ធនធាននៃភាពជាដៃគូ

ប្រភព៖ សូចនាករ និងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (https://indicators.report/targets/)

គោលបំណងនៃផែនទីបង្ហាញផ្លូវស្តីពី ការអភិវឌ្ឍជំនាញ គឺជាឯកសារណែនាំយុទ្ធសាស្ត្រសម្រាប់ក្រសួងពាក់ព័ន្ធ ស្ថាប័នសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញ។ តួអង្គពាក់ព័ន្ធនឹងរៀបចំនិងអនុវត្ត "ផែនការនិងយុទ្ធសាស្ត្រវិស័យជាក់លាក់" របស់ខ្លួនឆ្ពោះទៅរកការសម្រេច "គោលបំណង" គន្លឹះដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវ។ លើសពីនេះទៀតផែនទីបង្ហាញផ្លូវនេះបង្ហាញពីសកម្មភាពដែលកំណត់ពេលវេលាជាក់លាក់ សម្រាប់តួអង្គពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធ្វើការអភិវឌ្ឍជំនាញ។

អភិក្រមប្រើប្រាស់សម្រាប់រៀបចំផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ

ផែនទីបង្ហាញផ្លូវនេះបានរៀបចំដោយប្រើវិធីសាស្ត្រជា ៣ ដំណាក់កាលដាច់ៗពីគ្នា ប៉ុន្តែមានភាពប្រទាក់ក្រឡាគ្នា និងមានការចាត់ថ្នាក់យ៉ាងទូលំទូលាយ មានដូចជាដំណាក់កាលរៀបចំ និងអភិវឌ្ឍន៍ ដំណាក់កាលពិនិត្យឡើងវិញ និងដំណាក់កាលបញ្ចប់។ រូបភាពខាងក្រោមបង្ហាញអំពីដំណាក់កាលទាំងនេះ៖



ដំណាក់កាលនីមួយៗដែលបានរៀបរាប់ខាងលើ មានការពន្យល់លម្អិតដូចខាងក្រោម៖

- *ដំណាក់កាលរៀបចំ និងអភិវឌ្ឍ (Design and development phase)*៖ ដំណាក់កាលនេះចាប់ផ្តើមជាមួយនឹងការស្រាវជ្រាវលើឯកសារដែលមានស្រាប់យ៉ាងទូលំទូលាយ អំពីឧត្តមានុវត្តន៍អន្តរជាតិអំពីរចនាសម្ព័ន្ធនៃការអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលផ្តោតលើ៖ ស្តាប់ឯនអនុវត្តសំខាន់ៗ, តួអង្គជំរុញ, អ្នកទទួលផល និងកំណត់រកនូវបញ្ហា និងការប្រឈមនៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់ប្រទេសកម្ពុជា។ លើសពីនេះ ធាតុចូលពីការស្រាវជ្រាវបានផ្តល់ជាមូលដ្ឋាន សម្រាប់ការរៀបចំសេចក្តីព្រាងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនេះ ព្រមទាំងការកំណត់ទិសដៅសម្រាប់អនុវត្តការងារក្នុងដំណាក់កាលបន្តបន្ទាប់។
- *ដំណាក់កាលពិនិត្យឡើងវិញ (Review phase)*៖ ដំណាក់កាលនេះផ្តោតលើការផ្សព្វផ្សាយសេចក្តីព្រាងនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ ដែលបានរៀបចំនៅក្នុងដំណាក់កាលដំបូង

ដល់តួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីប្រមូលធាតុចូល និងមតិយោបល់ តាមរយៈកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយ (ដោយសារត្រូវរក្សាវិធានសុខាភិបាលបង្ការជំងឺកូវីដ-១៩)។

- *ដំណាក់កាលបញ្ចប់ (Finalization phase)*៖ ដំណាក់កាលនេះត្រូវបានអនុវត្តក្នុងគោលបំណងរៀបចំសេចក្តីព្រាងចុងក្រោយនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ តាមរយៈធាតុចូលនិងមតិយោបល់ទទួលបាននៅក្នុងដំណាក់កាលទី ២ បន្ទាប់ពីបានកែសម្រួលផ្អែកលើធាតុចូល និងមតិយោបល់ដែលប្រមូលបានពីតួអង្គពាក់ព័ន្ធទាំងអស់។ បន្ទាប់ពីបានកែសម្រួលរួចរាល់ សេចក្តីព្រាងនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ ត្រូវបានដាក់ឆ្លងក្នុងកិច្ចប្រជុំពិភាក្សាចុងក្រោយ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងស្នើសុំការឯកភាពពីគ្រប់តួអង្គពាក់ព័ន្ធក្នុងគោលដៅបន្តឆ្ពោះទៅជំហានបន្ទាប់ទៀត ។

ជារួម ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ បានរៀបចំឡើងផ្អែកលើ**អភិក្រម Top-down និង Bottom-up ដើម្បីធានានូវតុល្យភាពរវាងគោលនយោបាយ និងកម្មវិធីថ្នាក់ជាតិ ហើយបង្កបរិយាកាសនិងផ្តល់ជាការបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍជំនាញនៅក្នុងប្រទេសកម្ពុជា ព្រមទាំងកំណត់បញ្ហាប្រឈមគន្លឹះជារចនាសម្ព័ន្ធក្នុងការអភិវឌ្ឍនជំនាញ។** ក្នុងន័យនេះ អភិក្រម Bottom-up ដាក់បញ្ចូលនូវការចូលរួមនិងតួនាទីរបស់ក្រសួង-ស្ថាប័នរដ្ឋ និងតួអង្គពាក់ព័ន្ធដទៃទៀតក្នុងការអភិវឌ្ឍជំនាញ តាមរយៈការរៀបចំសិក្ខាសាលាតាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ ដើម្បីពិគ្រោះយោបល់ និងទទួលយកការឯកភាពលើការរៀបចំសេចក្តីព្រាងផែនទីចង្អុលផ្លូវខាងលើ។

ផែនទីបង្ហាញផ្លូវនេះផ្តោតសំខាន់លើលទ្ធផល បរិយាបន្ន ការអនុវត្ត និងសមិទ្ធកម្មនៃការអនុវត្ត ព្រមទាំងបានកំណត់នូវចក្ខុវិស័យរយៈពេលវែង សមស្របតាមចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលតាមរយៈការដាក់ចេញនូវ៖ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥, គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣, គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត, ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ និងផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០។

គួរកត់សម្គាល់ផងដែរថា ផ្នែកបន្ទាប់ក្នុងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនេះ នឹងលម្អិតអំពីសរសរស្តម្ភ ៥ និងគោលដៅគន្លឹះដែលផ្អែកលើចក្ខុវិស័យថ្នាក់ជាតិ គោលនយោបាយ និងឯកសារយុទ្ធសាស្ត្រ រួមជាមួយសូចនាករសមិទ្ធកម្ម ក្របខ័ណ្ឌពេលវេលា និងគណៈកម្មការអន្តរក្រសួង-ស្ថាប័នដែលបានកំណត់សម្រាប់អនុវត្តស្របតាមគោលបំណងនីមួយៗ។

ទិដ្ឋភាពទូទៅនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ

ស្របតាមកម្មវិធី និងគោលនយោបាយថ្នាក់ជាតិ ផែនទីបង្ហាញផ្លូវបានចែកចេញជា**សសរស្តម្ភយុទ្ធសាស្ត្រចំនួន ៥** ដែលមានគោលបំណងប្រទាក់ក្រឡាគ្នា។ សសរស្តម្ភ និងគោលបំណងគន្លឹះទាំងនេះត្រូវបានកំណត់ដោយសង្កត់ធ្ងន់ទៅលើរបៀបដោះស្រាយប្រព័ន្ធអេកូឡូស៊ីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់កម្ពុជា។ រូបភាពខាងក្រោមផ្តល់ជាភាពទូទៅនៃសសរស្តម្ភនៃផែនទីបង្ហាញផ្លូវ៖

ទិដ្ឋភាពទូទៅនៃសសរស្តម្ភយុទ្ធសាស្ត្រផែនទីបង្ហាញផ្លូវ

គោលបំណងគន្លឹះ និងសូចនាករអនុវត្ត

ផែនទីបង្ហាញផ្លូវនេះ មានគោលបំណងគន្លឹះសរុបចំនួន ២៦ និងសូចនាករសមិទ្ធកម្មគន្លឹះចំនួន ២៧ ដែលគាំទ្រឱ្យសរសរស្តម្ភយុទ្ធសាស្ត្រទាំង ៥។

តារាងខាងក្រោមសង្ខេបពីគោលបំណងគន្លឹះ ដែលបានកំណត់ទៅតាមសសរស្តម្ភនីមួយៗ៖

លរ	សសរស្តម្ភ	គោលបំណងគន្លឹះ	សូចនាករអនុវត្តន៍ដែលបានស្នើឡើង
១.	**ការពង្រឹងគុណ-ភាព និងស្តង់ដា**	• ឆ្ពោះទៅរកការអនុវត្តពេញលេញនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា • ការកែលម្អការកសាងសមត្ថភាពគ្រូបច្ចេកទេស • ការអភិវឌ្ឍកញ្ចប់ម៉ូឌុលបណ្តុះបណ្តាលម៉ូឌុលសិក្សាតាមអនឡាញ ឬពីចម្ងាយ និងការរួមបញ្ចូលជំនាញទន់នៅក្នុងកម្មវិធី TVET ទាំងអស់ • ការធ្វើបរិវត្តកម្ម ការប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាល (តាមរយៈការកែលម្អបរិក្ខារូបវន្តបណ្តុះបណ្តាលដោយយកចិត្តទុកដាក់ដល់យេនឌ័រ និងការរៀបចំដែលសន្សំសំចៃថាមពល) និងប្រែ-ក្លាយស្ថានភាពបច្ចុប្បន្នរបស់ពួកគេអាចបំពេញមុខងារជាគ្រឹះស្ថាន TVET ភូមិភាគ • ការផ្តល់ការបណ្តុះបណ្តាលជំនាញសម្រាប់តម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគតរួមមានបដិវត្តន៍ឧស្សាកម្ម ៤.០ និងសេដ្ឋកិច្ចបៃតង • ការពង្រឹងក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានស្រាប់ • ការយកលំនាំតាមអភិក្រមអប់រំ និងវិធីសាស្ត្រជំនាញចម្រុះ	• ចំនួនស្តង់ដាសមត្ថភាពដែលបានកំណត់នៅក្នុងឧស្សាហកម្មនីមួយៗ • ចំនួនគ្រូឧទ្ទេសដែលបានបណ្តុះបណ្តាល • ចំនួនសិក្ខាកាមដែលបានបណ្តុះបណ្តាល • ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលដែលបានកែលម្អ • ចំនួនវគ្គបណ្តុះបណ្តាលកម្រិតខ្ពស់ដែលបានបង្កើតនិងអនុវត្ត • ចំនួនស្តង់ដាសមត្ថភាពតាមមុខរបរដែលបានបង្កើតឡើងសម្រាប់ឧស្សាហកម្ម ៤.០ និងសេដ្ឋកិច្ចបៃតង • ចំនួនក្រុមប្រឹក្សាជំនាញតាមវិស័យដែលបានពង្រឹង • គោលនយោបាយអប់រំថ្មីដែលមានវិធីសាស្ត្ររួមបញ្ចូលគ្នា (ការអប់រំ និងការបង្កើនជំនាញ)
២.	**ការលើកកម្ពស់កិត្តិនាម និងការផ្សព្វផ្សាយ**	• ការបង្កើនការចូលរួម និងការយល់ដឹងអំពីការបណ្តុះបណ្តាលជំនាញ	• បង្កើតយុទ្ធសាស្ត្រកសាងកិត្តិនាមសម្រាប់ "ជំនាញកម្ពុជា" • % នៃកំណើនសិស្សចុះឈ្មោះ

លរ	សសរស្តម្ភ	គោលបំណងគន្លឹះ	សូចនាករអនុវត្តន៍ដែលបានស្នើឡើង
		• ការផ្តោតលើការកសាងកិត្តិនាម ការប្រឹក្សាយោបល់ និងការតស៊ូមតិ • ការកែលម្អលទ្ធភាពចូលរៀនរបស់ក្រុមងាយរងគ្រោះ • ការលើកកម្ពស់សហគ្រិនភាព • ការផ្តល់ឱកាសក្នុងការហ្វឹកហ្វឺនកូន-ជាង សម្រាប់ការងារ	• ភាគរយនៃកំណើនការងារសម្រាប់សិស្សបញ្ចប់ការសិក្សាពី TVET • ភាគរយនៃកំណើនការចុះឈ្មោះចូលរៀនរបស់ក្រុមជនងាយរងគ្រោះ • ភាគរយនៃកំណើនបេក្ខជនដែលក្លាយជាសហគ្រិន • ភាគរយនៃកំណើនការហ្វឹកហ្វឺនកូនជាងសម្រាប់សិស្សបញ្ចប់ការសិក្សា TVET
៣.	**TVET ឆ្លើយតបនឹងឧស្សាហកម្ម**	• ការលើកកម្ពស់តួនាទី និងការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍជំនាញ • ការពង្រឹងការផ្សារភ្ជាប់គ្នារវាងគ្រឹះស្ថាន TVET និងឧស្សាហកម្ម • ការលើកកម្ពស់ការកសាងជំនាញឡើងវិញ និងការបង្កើនជំនាញ • បង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យបន្ថែមទៀត	• ចំនួនកម្មវិធីភាពជាដៃគូឧស្សាហកម្ម ដែលត្រូវបានអនុវត្ត • ចំនួនកន្លែងការងារនៅឧស្សាហកម្មដែលទទួលបានជោគជ័យ រួមមាន ការចុះកម្មសិក្សា និង/ឬការចុះហាត់ការ • ភាគរយនៃកំណើនការងារសម្រាប់យុវជន • ភាគរយនៃកម្លាំងពលកម្មដែលមានស្រាប់បានបង្កើនជំនាញ ឬបណ្តុះជំនាញថ្មី/ ឆ្លង-កាត់កម្មវិធីសិក្សាផ្អែកលើការងារ • ចំនួនក្រុមប្រឹក្សាជំនាញតាមវិស័យថ្មី ដែលបានបង្កើតនិងមានដំណើរការ
៤.	**អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ**	• ការបង្កើនប្រសិទ្ធភាពនៃភាពជាអ្នក-ដឹកនាំ/យន្តការនៅគ្រឹះស្ថាន TVET • ការធ្វើឱ្យប្រសើរឡើងនូវការរួមបញ្ចូលគ្នា និងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងគ្រប់តួអង្គពាក់ព័ន្ធនៅក្នុងប្រព័ន្ធ TVET • ការបង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព • ការពង្រឹងប្រសិទ្ធភាពទិន្នន័យសម្រាប់ការធ្វើផែនការនិងការសម្រេចចិត្ត • ការលើកកម្ពស់គណនេយ្យភាព និងការផ្តល់ស្វ័យភាពដល់គ្រឹះស្ថាន TVET	• ការពង្រឹង និងផ្តល់អំណាចដល់គណៈកម្មាធិការជាតិបណ្តុះបណ្តាលលើតួនាទី និងការទទួលខុសត្រូវដែលបានកែសម្រួល • ការកំណត់សូចនាករដែលផ្តោតលើមុខងារនៃប្រព័ន្ធ TVET និងជំរុញរបៀបវារៈសម្រាប់ការអភិវឌ្ឍជំនាញតាមរយៈគោលនយោ-បាយអន្តរវិស័យ • ចំនួនវិវាទគោលនយោបាយអន្តរក្រសួង/ស្ថាប័ន ត្រូវបានកំណត់ និងដោះស្រាយ • ប្រព័ន្ធនិងដំណើរការត្រួតពិនិត្យ និងវាយ-តម្លៃ ត្រូវបានបង្កើតឡើង • ចំនួនស្ថាប័នស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើង

លរ	សសរស្តម្ភ	គោលបំណងគន្លឹះ	សូចនាករអនុវត្តន៍ដែលបានស្នើឡើង
		• ការបង្កើតផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍ TVET - ក្រុមផ្តល់យោបល់សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតួអង្គពាក់ព័ន្ធផ្សេងទៀតសម្រាប់ TVET	
៥.	**ការផ្តល់ហិរញ្ញ-ប្បទាន និងចីរភាព**	• លើកកម្ពស់ប្រសិទ្ធផល (ផលិត-ភាព) និងស័ក្តិសិទ្ធិភាព (បច្ចុប្បន្ន) នៃយន្តការផ្តល់មូលនិធិដែលមាន-ស្រាប់របស់មូលនិធិអភិវឌ្ឍន៍ជំនាញ • ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុនៃគ្រឹះស្ថានបណ្តុះបណ្តាលសាធារ-ណៈឆ្ពោះទៅរកការអនុវត្តផ្អែកលើលទ្ធផល និងស្វ័យភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញ • បង្កើនវិភាជន៍ថវិកាជាតិសម្រាប់ TVET/ការអភិវឌ្ឍជំនាញ • បង្កើនប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធ និងមូលនិធិដែលមានស្រាប់ពីដៃគូដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ វិស័យឯកជន។ល។	• ការផ្តល់មូលនិធិដោយផ្សារភ្ជាប់ទៅនឹងលទ្ធផលចុងក្រោយរបស់គម្រោង/កម្មវិធី • បង្កើតសូចនាករស្តីពីភាពជោគជ័យរបស់មូលនិធិអភិវឌ្ឍន៍ជំនាញ • ការរួមបញ្ចូលកម្មវិធី/គម្រោងផ្សេងៗគ្នា

តួនាទីរបស់តួអង្គពាក់ព័ន្ធសំខាន់ៗ

គោលបំណងនៃសសរស្តម្ភនីមួយៗក្នុងផែនទីបង្ហាញផ្លូវអាចសម្រេចបាន តាមរយៈការចូលរួមចំណែក និងការចូលរួមរបស់តួអង្គពាក់ព័ន្ធសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ី TVET នៅកម្ពុជា។ តារាងខាងក្រោម បង្ហាញពីតួនាទីរបស់រាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ វិស័យឯកជន (ឧស្សាហកម្ម និងនិយោជក) អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានបណ្តុះបណ្តាល សហគមន៍ (ទីប្រឹក្សាអាជីព អ្នកសិក្សា ឪពុកម្តាយ និងគ្រូបង្រៀន) អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ក្នុងការកសាងប្រព័ន្ធអេកូឡូស៊ី TVET ជុំវិញសសរស្តម្ភទាំង៥ នៃផែនទីបង្ហាញផ្លូវស្តីពី ការអភិវឌ្ឍជំនាញ។

ល.រ	សសរស្តម្ភ	តួនាទីរបស់តួអង្គពាក់ព័ន្ធ
១.	**ការពង្រឹងគុណភាព និងស្តង់ដា**	**រាជរដ្ឋាភិបាលកម្ពុជា & ក្រសួងពាក់ព័ន្ធ** • ជំរុញអន្តរាគមន៍តាមរយៈការសម្របសម្រួលរបស់គណៈកម្មាធិការដឹកនាំ ដែលមានការចូលរួមពីតំណាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឧស្សាហកម្ម និយោជក និងនិយោជិក • ដើរតួជាអ្នកថែរក្សាក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ដើម្បីធានាបាននូវអនុលោមភាព ការពង្រឹង និងការត្រួតពិនិត្យជាប្រចាំ។ **វិស័យឯកជន** • ផ្តល់នូវធាតុចូលខាងផ្នែកតម្រូវការក្នុងការអភិវឌ្ឍគុណវុឌ្ឍិ និងស្តង់ដារ ដោយមានតំណាងពីថ្នាក់ដឹកនាំក្នុងវិស័យឧស្សាហកម្ម, សហព័ន្ធនិយោជក, ក្រុមអ្នកផ្តល់យោបល់ ដើម្បីធានាបាននូវភាពបន្សុីគ្នាទៅនឹងឧស្សាហកម្ម។ **អ្នកផ្តល់ការបណ្តុះបណ្តាល, គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល** • ផ្តល់នូវធាតុចូលផ្នែកផ្តត់ផ្តង់អំពីសេចក្តីរំពឹងទុករបស់អ្នកចូលរួមកម្មវិធីបណ្តុះបណ្តាលនៅគ្រប់ក្រុមគោលដៅផ្សេងៗគ្នា ដូចជាស្ត្រី ក្រុមងាយរងគ្រោះ និង សិស្សបោះបង់ការសិក្សា។ល។ **សហគមន៍** • កែសម្រួល TVET ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមសហគមន៍, ធានាថា ស្តង់ដា TVET កំពុងត្រូវបានអនុវត្ត និងអនុលោមតាមគោលការណ៍ណែនាំ និងក្របខ័ណ្ឌចាំបាច់ទាំងអស់ • ផ្តល់ធាតុចូល និងមតិយោបល់ លើស្តង់ដាមុខរបរ និងគំរូកម្មវិធីសិក្សាដែលបានរៀបចំ • ផ្តល់ធាតុចូលលើសេចក្តីរំពឹងទុករបស់អ្នកសិក្សា បញ្ហាក្នុងតំបន់ និងបញ្ហា (សង្គម សេដ្ឋកិច្ច ការអប់រំ) សម្រាប់ការបណ្តុះបណ្តាលដែលផ្អែកលើតម្រូវការ • រៀបចំសិក្ខាសាលាផ្សព្វផ្សាយការយល់ដឹង និងពិគ្រោះយោបល់ជាប្រចាំ ដើម្បីពិភាក្សាអំពីនិន្នាការថ្មីៗ និងកំណែទម្រង់ • ផ្តល់មតិយោបល់ឱ្យបានទាន់ពេលវេលាលើគុណភាពនៃការបណ្តុះបណ្តាល។ **អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ** • គាំទ្ររាជរដ្ឋាភិបាល និងក្រសួង ដើម្បីបន្សុីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាជាមួយនឹងស្តង់ដាអន្តរជាតិ និងចែករំលែកនូវបទពិសោធន៍ល្អៗពីអន្តរជាតិ សម្រាប់ការអភិវឌ្ឍគុណភាព និងស្តង់ដារ

ល.រ	សសរស្តម្ភ	តួនាទីរបស់តួអង្គពាក់ព័ន្ធ
		• ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសលើការបណ្តុះបណ្តាលយុទ្ធសាស្ត្រ និងរៀបចំបង្កើតទីតាំងបណ្តុះបណ្តាល និងផ្តល់ឧបករណ៍និងប្រព័ន្ធបច្ចេកវិទ្យា។
២.	**ការលើកកម្ពស់កិត្តិនាម និងការផ្សព្វផ្សាយ**	**រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង** • ដើរតួនាទីជាអ្នកដឹកនាំ ក្នុងការផ្តល់ទិសដៅកសាងកិត្តិនាម ស្របគ្នាទៅតាមយុទ្ធសាស្ត្រ និងផែនការជាតិដទៃទៀត • សម្របសម្រួលជាមួយតួអង្គពាក់ព័ន្ធ (ឧស្សាហកម្ម និងស្ថាប័ន) ដើម្បីអប់រំ និងពង្រឹងការអនុវត្តតាមយុទ្ធសាស្ត្រកសាងកិត្តិនាម • បង្កើតគោលនយោបាយ និងកម្មវិធីលើកកម្ពស់លទ្ធភាពទទួលបានការបណ្តុះបណ្តាលរបស់ក្រុមងាយរងគ្រោះ និងលើកកម្ពស់សហគ្រិនភាព។ **វិស័យឯកជន** • គាំទ្រយុទ្ធនាការកសាងកិត្តិនាមដោយផ្តល់នូវការអនុវត្តជាក់ស្តែងដែលពាក់ព័ន្ធ និងបទពិសោធន៍ជោគជ័យនៃភាពជាដៃគូជាមួយឧស្សាហកម្ម • ផ្តល់ការណែនាំនិងឱកាសសម្រាប់ការអភិវឌ្ឍសហគ្រិនភាព ការហ្វឹកហ្វឺនកូនជាង។ល។ **អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល** • ធានាបាននូវការអនុវត្តយុទ្ធសាស្ត្រកសាងកិត្តិនាមទូទាំងប្រទេស ប្រកបដោយប្រសិទ្ធភាព និងការប្រើប្រាស់សម្ភារអប់រំផ្សព្វផ្សាយ • ទាក់ទាញសិស្សឱ្យចូលរួមតាមរយៈការប្រើប្រាស់សារ ត្រឹមត្រូវ ដើម្បីជំរុញភាពជឿជាក់លើខ្លួនឯងរបស់សិស្ស និងការកសាងកេរ្តិ៍ឈ្មោះរបស់វិស័យអប់រំ **សហគមន៍** • ធានាថា បេក្ខជនយល់ដឹងពីអត្ថប្រយោជន៍របស់ TVET និងវិធីគាំទ្រពួកគេក្នុងការអភិវឌ្ឍអាជីព • កំណត់អត្តសញ្ញាណអ្នកទទួលផល និងធ្វើឱ្យសហគមន៍មានការយល់ដឹងពីគម្រោង និងកម្មវិធី TVETនានា នៅថ្នាក់តំបន់/ថ្នាក់ខេត្ត • ជួយកសាងមុខមាត់នៃប្រព័ន្ធអេកូឡូស៊ី TVET កម្ពុជា នៅកម្រិតសកល ដើម្បីបង្កើតសេចក្តីប្រាថ្នាផ្នែកជំនាញ។

ល.រ	សសរស្តម្ភ	តួនាទីរបស់តួអង្គពាក់ព័ន្ធ
		អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ • ផ្តល់ការគាំទ្រដល់យុទ្ធនាការទីផ្សារតាមរយៈការបង្កើនទម្រង់នៃ "ជំនាញកម្ពុជាដែលមានគុណប្រយោជន៍" ជាមួយនឹងភាពជាដៃគូអន្តរជាតិ, ការចូលរួមរបស់ភ្នាក់ងារផ្សព្វផ្សាយ និងការផ្សព្វផ្សាយជាសាធារណៈស្របទៅតាមយុទ្ធសាស្ត្រជាតិកសាងកិត្តិនាម។
៣.	TVET ឆ្លើយតបនឹងឧស្សាហកម្ម	**រាជរដ្ឋាភិបាលកម្ពុជា & ក្រសួង** • អនុវត្តគោលនយោបាយ និងការលើកទឹកចិត្ត (ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ) ដើម្បីលើកទឹកចិត្តដល់កម្មវិធីភាពជាដៃគូផ្អែកលើតម្រូវការឧស្សាហកម្ម • ផ្តល់នូវសេវាកម្មផ្គូផ្គងការងារប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយថ្លៃដើម និងភាពអត់ការងារធ្វើរយៈពេលវែង (ច្រើនជាង៦ខែ)។ **វិស័យឯកជន** • ដើរតួជាភ្នាក់ងារជំរុញភាពផ្លាស់ប្តូរដោយទទួលស្គាល់ការបណ្តុះបណ្តាលជំនាញ និងបង់ថ្លៃបុព្វលាភជំនាញដល់កម្លាំងពលកម្មជំនាញ • ចូលរួមយ៉ាងសកម្មតាមរយៈការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នានៅគ្រប់ដំណាក់នៃការបណ្តុះបណ្តាល ដូចជា ការអភិវឌ្ឍកម្មវិធីសិក្សា, បាឋកថារបស់វាគ្មិន, ការបណ្តុះបណ្តាលដោយការបំពេញការងារផ្ទាល់, ការផ្តល់ការងារ។ល។ • ធ្វើបច្ចុប្បន្នភាពគ្រឹះស្ថានបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍចុងក្រោយលើការគ្រប់គ្រងធនធានមនុស្ស និង ទំនាក់ទំនងឧស្សាហកម្ម **អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល** • ដឹកនាំគម្រោង និងកម្មវិធីភាពជាដៃគូឧស្សាហកម្ម • ធ្វើការរួមគ្នាជាមួយឧស្សាហកម្ម ដើម្បីបង្កើត ក្របខ័ណ្ឌជំនាញដែលអាចទុកចិត្តបានដែលសិក្ខាកាមអាចកំណត់អត្តសញ្ញាណជាមួយនិយោជក។ **សហគមន៍** • ការចូលរួមយ៉ាងសកម្មពីសហគមន៍ក្នុងការរៀបចំបង្កើតភាពជាដៃគូ • ផ្តល់ជូននូវធនធាន និងការផ្សារភ្ជាប់ (ផ្តោតលើអាជីវកម្មក្នុងមូលដ្ឋាន) ទៅនឹងគ្រឹះស្ថាន TVET។

ល.រ	សសរស្តម្ភ	តួនាទីរបស់តួអង្គពាក់ព័ន្ធ
		អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ • អនុម័តគម្រោង និងកម្មវិធីសាកល្បងភាពជាដៃគូឧស្សាហកម្ម ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ សកម្មភាពនេះនឹងផ្តល់នូវកម្លាំងរុញច្រាន និងនិចលភាពចាំបាច់ • ផ្តល់នូវការយល់ដឹងពាក់ព័ន្ធលើការផ្លាស់ប្តូរឧស្សាហកម្មនិងទិដ្ឋភាពសេដ្ឋកិច្ចសកល ឬក្នុងតំបន់ ដែលអាចជះឥទ្ធិពលដល់ ស្ថានភាពរបស់ប្រទេសកម្ពុជា។
៤.	**អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ**	**រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង** • រៀបចំ និងអនុវត្តការបង្កើតក្រុមប្រឹក្សាជំនាញខ្ពស់បំផុត ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធសំខាន់ៗ (ឧ. អ្នកដឹកនាំឧស្សាហកម្មគន្លឹះ អ្នកសិក្សា និងក្រុមអ្នកផ្តល់យោបល់ល។) • សម្របសម្រួលការប្រជុំក្រុមប្រឹក្សា ដើម្បីកំណត់ និងដោះស្រាយបញ្ហាគោលនយោបាយ និងភាពមិនប្រទាក់ក្រឡាគ្នានៃអន្តរក្រសួង/ស្ថាប័ននានា។ **វិស័យឯកជន** • ចូលរួមក្នុងជាអ្នកតួអង្គពាក់ព័ន្ធសំខាន់ៗ (តំណាងឱ្យឧស្សាហកម្ម និងនិយោជិក) ក្នុងការធានានូវភាពជោគជ័យនៃប្រព័ន្ធអភិបាលកិច្ច ដែលបង្កើតឡើងសម្រាប់ប្រព័ន្ធអេកូឡូស៊ី TVET • ចូលរួមចំណែកក្នុងការកសាងប្រព័ន្ធអេកូឡូស៊ី តាមរយៈការស្រាវជ្រាវ និងការអភិវឌ្ឍ។ **អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល** • ដើរតួជាអ្នកពាក់ព័ន្ធ នៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ច TVET ដែលមានស្រាប់ដើម្បីជួយតម្រង់ទិសដៅគោលនយោបាយ និងការសម្របសម្រួល • ផ្តល់នូវការគាំទ្រក្នុងការធ្វើសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍នៅកម្ពុជា (ផ្តោតលើការវាយតម្លៃ បច្ចុប្បន្នភាពនៃកម្មវិធីអភិវឌ្ឍន៍ជំនាញដែលមានស្រាប់ និងការអភិវឌ្ឍសៀវភៅ "ស" (White Papers) ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ)។

ល.រ	សសរស្តម្ភ	តួនាទីរបស់តួអង្គពាក់ព័ន្ធ
		សហគមន៍ • ការចូលរួមយ៉ាងសកម្មរបស់សង្គមស៊ីវិល និងដៃគូសង្គមក្នុងគោលនយោបាយ និងការសម្រេចចិត្តក្នុងបរិបទទូលំទូលាយនៃការផ្លាស់ប្តូរគំរូ ពីលំនាំគ្រប់គ្រងបែបប្រពៃណី ទៅលក្ខណៈពហុតួអង្គពាក់ព័ន្ធនៃគោលគំនិតអភិបាលកិច្ច។ **អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ** • ផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធីពាក់ព័ន្ធដែលបង្កើតលទ្ធផល និងបច្ច័យត្រឹមត្រូវ • ផ្តល់នូវការយល់ដឹងពាក់ព័ន្ធលើការផ្លាស់ប្តូរឧស្សាហកម្មនិងទិដ្ឋភាពសេដ្ឋកិច្ចសកល ឬក្នុងតំបន់ ដែលប៉ះពាល់ដល់ ជៈឥទ្ធិពលដល់ស្ថានភាពរបស់ប្រទេសកម្ពុជា • រៀបចំវេទិកាសម្រាប់កិច្ចសហការអន្តរជាតិដើម្បីពង្រឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅក្នុងវិស័យនេះ។
៥.	**ការផ្តល់ហិរញ្ញប្បទាន និងចីរភាព**	**រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង** • រៀបចំក្របខ័ណ្ឌគោលនយោបាយ និងធ្វើការសម្រេចចិត្តលើយន្តការផ្តល់មូលនិធិ ដែលរួមមាន ការលើកទឹកចិត្តផ្នែកពន្ធ។ កម្មវិធី/គម្រោងផ្សេងៗគ្នាអាចប្រើការលើកទឹកចិត្តផ្សេងៗគ្នា (ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ)។ **វិស័យឯកជន** • ដើរតួជាម្ចាស់គម្រោង/កម្មវិធី ដើម្បីធានានូវការអនុវត្តប្រកបដោយជោគជ័យ • ទទួលខុសត្រូវចំពោះការអនុវត្តសូចនាករដែលបានកំណត់ និងឯកភាពគ្នាទៅវិញទៅមក សម្រាប់គម្រោង/កម្មវិធីផ្សេងៗ។ **អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល** • ផ្តល់លំនាំនៃចំណូលនិងចំណាយ ដើម្បីផ្តល់នូវសក្តានុពលភាពសម្រាប់និរន្តរភាពផ្នែកហិរញ្ញវត្ថុ • តាមដានការប្រើប្រាស់ថវិកាតាមសូចនាករ និងពេលវេលាដែលបានឯកភាពគ្នា។ **សហគមន៍** • គាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រឹះស្ថាន TVET ដើម្បីលើកកម្ពស់លទ្ធភាពទទួលបាន និងការផ្សព្វផ្សាយ ។

ល.រ	សសរស្តម្ភ	តួនាទីរបស់តួអង្គពាក់ព័ន្ធ
		• ដើរតួជាអ្នកពាក់ព័ន្ធដ៏សំខាន់ក្នុងការត្រួតពិនិត្យលើការប្រើប្រាស់មូលនិធិ TVET។ **អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ** • ផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធីពាក់ព័ន្ធបន្ថែមដែលបង្កើតនូវលទ្ធ-ផល និងផលជះត្រឹមត្រូវ។

ទោះបីជាសសរស្តម្ភ និងគោលបំណងដែលបានរៀបរាប់ខាងលើ ផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញផ្អែកលើលទ្ធផលលម្អិត និងមានការកំណត់ពេលវេលាជាក់លាក់ក៏ដោយ ចាំបាច់ណាស់ត្រូវមានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព។

ការត្រួតពិនិត្យ

ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព គឺជាគន្លឹះមូលដ្ឋានភ័ស្តុតាង នៃការរៀបចំផែនការ និងការសម្រេចចិត្ត ។ លើសពីនេះទៅទៀត ការផ្តល់ការរាយការណ៍វឌ្ឍនភាពជាប្រចាំស្តីពី "សកម្មភាពដែលបានអនុវត្ត និងសកម្មភាពដែលមិនអាចអនុវត្តទាន់ពេលវេលា" ក្នុងការធានានូវតម្លាភាព គណនេយ្យភាព និងការសិក្សាលើបរិបទគម្រោង។ ដូច្នេះ ដើម្បីធានានូវប្រសិទ្ធភាព នៃការអនុវត្តផែនទីបង្ហាញផ្លូវ គួរទទួលបានការគាំទ្រ លើការត្រួតពិនិត្យ និងវាយតម្លៃដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាល (គ.ជ.ប.ប) ដោយមានការគាំទ្រពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសារៈសំខាន់ណាស់។ ក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តវិស័យតាមបែបឌីជីថលត្រូវបានបង្កើតឡើង ដើម្បីក្តោបយកនូវវឌ្ឍនភាពនៅទូទាំងសរសរស្តម្ភ គោលបំណង និងសូចនាករ ដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវនេះ។ ក្នុងនោះ ច្រកចាប់យកជំនាញជាតិ អាចត្រូវបានបង្កើតឡើង ដោយរួមមានតួអង្គពាក់ព័ន្ធចំនួន៣ ៖ គ្រឹះស្ថានឧស្សាហកម្ម គ្រឹះស្ថានTVET និងការចូលរួមរបស់បុរស និងស្ត្រីដែលកង្វះការងារ។ តាមរយៈច្រកចាប់យកជំនាញជាតិ គ្រឹះស្ថានឧស្សាហកម្មនឹងត្រូវជូនដំណឹងអំពីតម្រូវការជំនាញរបស់ពួកគេ ចំពោះគ្រឹះស្ថាន TVET ត្រូវចុះឈ្មោះសម្រាប់ការបណ្តុះបណ្តាល ដូចនេះបុរសនិងស្ត្រីដែលកង្វះការងារអាចនឹងទទួលបានព័ត៌មានទាំងអស់ អំពីតម្រូវការនៃការអភិវឌ្ឍជំនាញរបស់ពួកគេ ។ បន្ទាប់មក ច្រកចាប់យកជំនាញជាតិ នឹងបញ្ជូលដើម្បីតាមដានសមិទ្ធផលនៃគោលដៅបណ្តុះបណ្តាលក្នុងពេលវេលាជាក់ស្តែង នឹងធ្វើការវាយតម្លៃលើបញ្ហាប្រឈមនានា និងបង្កើតយុទ្ធសាស្ត្រ

កាត់បន្ថយហានិភ័យ(តាមតម្រូវការ)។ តម្រូវការនៃការត្រួតពិនិត្យ និងឧបករណ៍ដែលត្រូវប្រើប្រាស់អាចត្រូវបានបង្កើតឡើងសម្រាប់សូចនាករនីមួយៗ ដើម្បីធានាភាពច្បាស់លាស់។

ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញលម្អិតសម្រាប់កម្ពុជាដែលរួមមានកិច្ចអន្តរាគមន៍ ដើម្បីសម្រេចទិសដៅនៃសរសរស្តម្ភទាំង៥ មានចែងក្នុងផ្នែកដូចខាងក្រោម។

សកម្មភាពតម្រង់ទិស និងពេលវេលានៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា

ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញដែលបានលើកឡើងនៅក្នុងផ្នែកនេះ គ្របដណ្តប់រាល់អន្តរាគមន៍ចាំបាច់ ដើម្បីសម្រេចគោលបំណងនៃសរសរស្តម្ភទាំង៥។ អន្តរាគមន៍នីមួយៗ ត្រូវបានចាត់ទៅតាមប្រភេទនៃគោលបំណង និងមានទិដ្ឋភាពដូចខាងក្រោម៖

- សូចនាករនៃការអនុវត្ត៖ វាស់វែងភាពជោគជ័យនៃអន្តរាគមន៍
- សូចនាករឆ្នាំមូលដ្ឋាន៖ វឌ្ឍនភាពដែលសម្រេចបាននៅឆ្នាំ២០២១ ប្រសិនបើអន្តរាគមន៍បានអនុវត្តរួចហើយ នៅក្នុងប្រព័ន្ធអេកូឡូស៊ី TVET បច្ចុប្បន្នក្នុងកម្មវិធី/គម្រោងណាមួយ
- គោលដៅប្រចាំឆ្នាំ៖ គោលដៅដែលត្រូវសម្រេច សម្រាប់អន្តរាគមន៍ក្នុងរយៈពេលខ្លី មធ្យម និងវែង
- ក្រសួង/ស្ថាប័នទទួលខុសត្រូវ៖ អង្គការ/ស្ថាប័នដែលទទួលខុសត្រូវចំពោះអន្តរាគមន៍
- ការបន្សុីនឹងយុទ្ធសាស្ត្រ៖ គោលនយោបាយនានា/គោលនយោបាយមានស្រាប់ទាំងឡាយណាដែលអន្តរាគមន៍បានបន្សុីជាមួយ
- ការបន្សុីនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលអន្តរាគមន៍នឹងចូលរួមចំណែកដល់៖

ល.រ	សរសេរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
1. ការពង្រឹងគុណភាព និងស្តង់ដា									
ឆ្ពោះទៅរកការអនុវត្តពេញលេញនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា									
១.១	បង្កើតក្របខ័ណ្ឌរួមមួយ ជាការណែនាំ/ដំណើការជាជំហានៗ ដើម្បីអភិវឌ្ឍ ពិនិត្យឡើងវិញ និងការអនុម័តកញ្ចប់ស្តង់ដា ជាតិតាមមុខរបរ/ គុណវុឌ្ឍិ	ការអនុលោមតាមក្របខ័ណ្ឌ នៅតាម ក្រុមប្រឹក្សាជំនាញតាមវិស័យទាំងអស់	គ្មានបន្ទាត់មូលដ្ឋាន	ក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានស្រាប់ទាំងបួន	ការអនុលោមតាម ក្រុមប្រឹក្សាជំនាញតាមវិស័យផ្សេងទៀត និងនៅពេលដែលវាត្រូវបានបង្កើតឡើង	ក្រុមប្រឹក្សាជំនាញតាមវិស័យ ដែលមានការគាំទ្រពី DGTVET ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ក.ប.)	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០/២០៥០	គោលដៅទី ៤
១.២	បង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍កម្មវិធីសិក្សា ជាឯកសារជាក់លាក់ដែលបង្ហាញពីប៉ារ៉ាម៉ែត្រដើម្បីជួយក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងកំណត់លទ្ធផលនៃការសិក្សា	ការអនុលោមតាមក្របខ័ណ្ឌអភិវឌ្ឍន៍កម្មវិធីសិក្សានៅតាមក្រុមប្រឹក្សាជំនាញតាមវិស័យ	គ្មានបន្ទាត់មូលដ្ឋាន	ក្រុមប្រឹក្សាជំនាញតាមវិស័យ ដែលមានស្រាប់ទាំងបួន	ការអនុលោមតាមក្រុមប្រឹក្សាជំនាញតាមវិស័យផ្សេងទៀត និងនៅពេលដែលវាត្រូវបានបង្កើតឡើង	ក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានការគាំទ្រពី DGTVET ក្រសួង ក.ប.	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០/២០៥០	គោលដៅទី ៤

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
១.៣	បង្កើតកញ្ចប់ស្តង់ដារជំនាញសមត្ថភាព (កញ្ចប់កម្មវិធីសិក្សា សម្ភារៈសិក្សា និងកញ្ចប់វាយតម្លៃសមត្ថភាព) លើវិស័យអាទិភាពបន្ថែមទៀត	ចំនួនវិស័យ / ឧស្សាហកម្មដែលកញ្ចប់ត្រូវបានបង្កើតឡើង	ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ២-៤ សម្រាប់វិស័យសំណង់ ការផលិតជាងម៉ាស៊ីន និងការងារអគ្គិសនី ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ៥ (ឌីប្លូម) សម្រាប់ការងារអគ្គិសនី	វិស័យកាត់ដេរ និង វាយនភ័ណ្ឌ	វិស័យទេសចរណ៍ អាហារនិង ភេសជ្ជៈ	ការជីករ៉ែ និងរុករករ៉ែ	ក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានការគាំទ្រពី DGTVET ក្រសួង ក.ប.	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០/២០៥០	គោលដៅទី ៤
១.៤	បង្កើតកម្មវិធីសិក្សានិងស្តង់ដាសមត្ថភាពសម្រាប់ការងារ / មុខរបរដែលទាក់ទងនឹងបដិវត្តឧស្សាកម្ម ៤.០ ជំនាញនាពេលអនាគត និងសេដ្ឋកិច្ចបៃតង។	ភាគរយនៃកម្មវិធីសិក្សានិងស្តង់ដាសមត្ថភាពត្រូវបានបង្កើតឡើងសម្រាប់កំណត់	គ្មានបន្ទាត់មូលដ្ឋាន	៣0%	៥0%	៨0%	ក្រសួង ក.ប. ក្រសួង អ.យ.ក.	ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ គោលនយោបាយជាតិមុខរបរ និងការងារឆ្នាំ២០១៥-២០២៥	គោលដៅទី ៤ ៧ និង ១៣

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
		តួនាទីភារកិច្ចការងារ						ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០/២០៥០	
១.៥	កំណត់ច្រកសម្រាប់ការចល័តទៅមក តាមកម្រិតសមត្ថភាពខុសៗគ្នាសម្រាប់ផ្នែកសិក្សាទាំងអស់ (បច្ចេកទេស និងបច្ចេកវិទ្យា ទូទៅ)	ឯកភាពគ្នាលើច្រក/ទិសដៅចល័តទៅមកនៅគ្រប់កម្រិតសិក្សា	ប្រព័ន្ធ TVET ដែលបានការឯកភាពពីគណៈកម្មាធិការជាតិបណ្តុះបណ្តាល (គ.ជ.ប.ប.) នៅខែធ្នូ ឆ្នាំ ២០០០ កម្រិតទិសដៅចល័តមួយចំនួនដែលមានស្រាប់	១	-	-	គណៈកម្មាធិការជាតិបណ្តុះបណ្តាល (គ.ជ.ប.ប.) DGTVET ក្រសួង ក.ប.	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣	គោលដៅទី ៤
១.៦	ការបន្សុំទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ទៅនឹងស្តង់ដាអន្តរជាតិ (ដូចជាប្រទេសសិង្ហបុរី ឥណ្ឌា)	ចំនួនក្របខ័ណ្ឌនៅក្នុងតំបន់ / សកលលោកដែលបន្សុំនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា	ក្នុងនាមជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្របខ័ណ្ឌគុណ	៥	១០	១៥	គណៈកម្មាធិការជាតិបណ្តុះបណ្តាល (គ.ជ.ប.ប.) DGTVET ក្រសួង ក.ប.	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣	គោលដៅទី ៤

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
			វុឌ្ឍិជាតិកម្ពុជាត្រូវបន្សុំទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិប្រចាំតំបន់						
១.៧	អនុវត្តប្រព័ន្ធធានាគុណភាពដោយផ្អែកលើក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាសម្រាប់ទាំងគ្រឹះស្ថាន TVET សាធារណៈ និងឯកជននៅទូទាំងប្រទេស	គ្រឹះស្ថាន TVET ទាំងអស់ អនុវត្តតាម	គ្រឹះស្ថាន TVET ទាំងអស់ ដែលស្ថិតនៅក្រោមក្រសួង ក.ប.គឺស្ថិតនៅក្រោមការធ្វើសវនកម្មគុណភាព	គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្រោមក្រសួងផ្សេងៗ	គ្រឹះស្ថាន TVET ទាំងអស់ដែលមិនមែនជាគ្រឹះស្ថាន	-	ក្រសួង ក.ប. ក្រសួង អ.យ.ក.គឺជាស្ថាប័នធានាដល់ការពិនិត្យនិងវាយតម្លៃ DGTVET	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០/២០៥០	គោលដៅទី ៤
១.៨	ការបន្សុំគ្នានៃកម្មវិធីដែលមានស្រាប់ដែលស្ថិតនៅក្រោមក្រសួងផ្សេងៗ ឱ្យត្រូវនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា	ភាគរយនៃវគ្គសិក្សា និងកម្រិតឱ្យស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា	កម្មវិធីទាំងអស់ដែលស្ថិតនៅក្រោមក្រសួង ក.ប. គឺស្របទៅនឹង ក្របខ័ណ្ឌ	១00% នៃវិស័យអាទិភាព នៅក្រោម IDP ឆ្នាំ២០១៥-២០២៥	ការបន្សុំនៃវិស័យដទៃទៀតដែលបានកំណត់សម្រាប់	ការបន្សុំនៃវិស័យដទៃទៀតដែលបានកំណត់សម្រាប់រយៈពេលនេះ	DGTVET ក្រសួង ក.ប. ក្រសួង អ.យ.ក និងក្រសួងពាក់ព័ន្ធផ្សេងៗទៀត	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣	គោលដៅទី ៤

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
			គុណវុឌ្ឍិជាតិកម្ពុជា		រយៈពេលនេះ			ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០/២០៥០	
១.៩	បង្កើតគោលការណ៍ណែនាំ/ លក្ខណវិនិច្ឆ័យសម្រាប់ទទួលស្គាល់គុណភាពវគ្គសិក្សាដែលអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ការបណ្តុះបណ្តាលឯកជនរួមមាន(មិនកំណត់)៖ • វិសាលភាព • ដំណើរការនៃការទទួលស្គាល់វគ្គបណ្តុះបណ្តាល • វគ្គបណ្តុះបណ្តាលជំនាញរដ្ឋបាល (រយៈពេលសម្ភារ បរិក្ខារ និងសមត្ថភាពគ្រូ។ល។)	ភាគរយនៃវគ្គសិក្សាដែលបានទទួលស្គាល់គុណភាព តាមគោលការណ៍ដែលបានបង្កើតឡើង	ការទទួលស្គាល់គុណភាពវគ្គសិក្សាដែលបានអភិវឌ្ឍហើយ ជាផ្នែកមួយនៃគម្រោង របស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB′s TVET SDP) ផ្នែកអគ្គិសនី និងការផលិត	៣0%	៥0%	៨0%	គណៈកម្មការស្តង់ដាជាតិ សមត្ថភាព និងធ្វើតេស្តនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០/២០៥០	គោលដៅទី ៤

ល.រ	សរសេរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
ការកែលម្អការកសាងសមត្ថភាពគ្រូបណ្តុះបណ្តាលរបស់ TVET									
១.១០	បង្កើតសៀវភៅណែនាំគោលនយោបាយធនធានមនុស្ស (HR) នៅទូទាំងប្រទេស សម្រាប់គ្រូឧទ្ទេស TVET ដែលគ្របដណ្តប់លើទិដ្ឋភាព (មិនកំណត់)៖ • បទដ្ឋាននៃការជ្រើសរើសបុគ្គលិក និងការដាក់ឱ្យប្រើប្រាស់ (រួមទាំងគ្រូឧទ្ទេស ដែលមានបទពិសោធន៍ផ្នែកឧស្សាហកម្ម វិទ្យាស្ថានបណ្តុះបណ្តាលជំនាញសាធារណៈ) • ប្រភពនៃការជ្រើសរើសបុគ្គលិក	ការអនុលោមតាមសៀវភៅណែនាំគោលនយោបាយធនធាន មនុស្ស ដោយ វិទ្យាស្ថាន TVET	គ្មានបន្ទាត់មូលដ្ឋាន	គ្រឹះស្ថាន TVET ទាំងអស់	គ្រប់គ្រឹះស្ថាន TVET សាធារណៈទាំងអស់ (លើកលែងតែវិទ្យាស្ថានបណ្តុះបណ្តាលជំនាញ)	គ្រឹះស្ថាន TVET ទាំងអស់ ដែលមិនមែនជាសាធារណៈ	DGTVET ក្រសួង ក.ប. ដោយមានការគាំទ្រពី ក្រសួង អ.យ.ក. និងក្រុមប្រឹក្សាជំនាញតាមវិស័យ	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០	គោលដៅទី ៤

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
	• ប្រភេទការងារ និងលក្ខណៈនៃការងារ • ការវាយតម្លៃ និងការជ្រើសរើស • បែបបទនៃការតែងតាំង • អត្ថប្រយោជន៍ផ្សេងៗ • ការសាកល្បង និងការបញ្ជាក់ • ផែនការសំណង								
១.១១	បង្កើតក្របខ័ណ្ឌរួមមួយសម្រាប់ការទទួលស្គាល់ គ្រូឧទ្ទេសឱ្យស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា	ការអនុលោមតាមក្របខ័ណ្ឌដែលបានបង្កើតឡើង	គ្មានបន្ទាត់មូលដ្ឋាន	វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស	គ្រប់គ្រឹះស្ថាន/ ក្រុមប្រឹក្សាជំនាញតាមវិស័យដែលអនុវត្តការបណ្តុះបណ្តាលគ្រូឧទ្ទេស		DGTVET ក្រសួង ក.ប. ដោយមានការគាំទ្រពីក្រសួង អ.យ.ក. និងក្រុមប្រឹក្សាជំនាញតាមវិស័យ	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០	

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
១.១២	បង្កើតគោលការណ៍ណែនាំទូទៅសម្រាប់ការបណ្តុះបណ្តាលគ្រូបង្គោលរួមមាន៖ • លក្ខខណ្ឌតម្រូវការចូល បំរើការងារ • រចនាសម្ព័ន្ធស្តង់ដានៃ ការបណ្តុះបណ្តាលគ្រូឧទ្ទេស • មាតិកាស្តង់ដា • លក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ • កម្រិត និងការផ្តល់គុណវុឌ្ឍិដល់គ្រូឧទ្ទេស	ការប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ណែនាំដែលបានបង្កើតឡើង	គ្មានបន្ទាត់មូលដ្ឋាន	វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស	គ្រប់វិទ្យាស្ថាន/ក្រុមប្រឹក្សាជំនាញតាមវិស័យ ដែលអនុវត្តការបណ្តុះបណ្តាលគ្រូឧទ្ទេស		DGTVET ក្រសួង ក.ប. ដោយមានការគាំទ្រពីក្រសួង អ.យ.ក. និងក្រុមប្រឹក្សាជំនាញតាមវិស័យ	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០	
១.១៣	ពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងសមត្ថភាពរបស់ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស	ភាគរយនៃបុគ្គលិក វិទ្យាស្ថានជាតិ	គ្រូឧទ្ទេសចំនួន ២០ នាក់របស់ វិទ្យាស្ថានជាតិ	៣០%	៥០%	៨០%	ក្រសួង ក.ប. ដោយមានការគាំទ្រពីក្រសួង អ.យ.ក. និង	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET	គោលដៅទី ៤

ល.រ	សរសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
	ទាក់ទងនឹងការបង្រៀនគរុកោសល្យ និងបច្ចេកទេសថ្មីៗ	បណ្តុះបណ្តាលបច្ចេកទេសដែលមានសមត្ថភាព	បណ្តុះបណ្តាលបច្ចេកទេស បានបណ្តុះបណ្តាលសាកល្បង (ឆ្នាំ២០១៦) គ្រូរបស់ TVET ចំនួន ៣០០ នាក់ នឹងបញ្ចប់ការសិក្សាពីវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ជារៀងរាល់ឆ្នាំ ចាប់ផ្តើមនៅក្នុងឆ្នាំ ២០១១				ក្រសួងផ្សេងៗទៀត	ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០/២០៥០	
១.១៤	កសាងសមត្ថភាពរបស់គ្រឹះស្ថាន TVET និង ក្រុមប្រឹក្សាជំនាញតាមវិស័យ ដើម្បី	ភាគរយនៃគ្រឹះស្ថាន TVET និង	គ្មានបន្ទាត់	គ្រឹះស្ថាន TVET៖ ១០%	គ្រឹះស្ថាន TVET៖ ២០%	គ្រឹះស្ថាន TVET៖ ៣០%	ក្រសួង ក.ប. ដោយមានការគាំទ្រពីក្រសួង អ.យ.ក.	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥	គោលដៅទី ៤

ល.រ	សរសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
	អនុវត្តការបណ្តុះបណ្តាលគ្រូឧទ្ទេស	ក្រុមប្រឹក្សាជំនាញតាមវិស័យ ដែលមានសមត្ថភាព	មូលដ្ឋាន	ក្រុមប្រឹក្សាជំនាញតាមវិស័យ៖ ចំនួន៤ ដែលមានស្រាប់	ក្រុមប្រឹក្សាជំនាញតាមវិស័យ៖ ក្រុមប្រឹក្សាជំនាញតាមវិស័យទើបបង្កើតថ្មី	ក្រុមប្រឹក្សាជំនាញតាមវិស័យ៖ ក្រុមប្រឹក្សាជំនាញតាមវិស័យទើបបង្កើតថ្មី	និងក្រសួងផ្សេងៗទៀត	ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០	
១.១៥	ការពង្រីកកម្មវិធីត្រឡប់ទៅឧស្សាហកម្មវិញ (RIS) សម្រាប់គ្រូដែលមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស	ចំនួននៃគ្រូបណ្តុះបណ្តាលដែលជាផ្នែកមួយនៃ RIS	គ្រូបណ្តុះបណ្តាល CBT ចំនួន ២៥៦ បានបញ្ចប់ RIS សម្រាប់វិស័យអាទិភាពដែលបានអនុវត្តក្រោមគម្រោង TVETSDP	៣០០	៤០០	៥០០	ក្រសួង ក.ប. ដោយមានការគាំទ្រពី ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ. និងក្រសួងផ្សេងៗទៀត	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ TVET ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០	គោលដៅទី ៤
ការបង្កើតកញ្ចប់បណ្តុះបណ្តាលម៉ូឌុល ម៉ូឌុលសិក្សាតាមអនឡាញ និងការរួមបញ្ចូលជំនាញទន់នៅក្នុងកម្មវិធី TVET ទាំងអស់									

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
១.១៦	បង្កើតម៉ូឌុលសម្រាប់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដោយផ្អែកលើកម្មវិធី TVET ដែលមានស្រាប់	ភាគរយនៃវគ្គសិក្សាតាមឌីជីថលដែលបានបង្កើតឡើង	UNIDO បានបង្កើតម៉ូឌុលឌីជីថលសម្រាប់វិស័យ T&A	៣0%	៥0%	១00%	ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ.	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥ ក្របខ័ណ្ឌគោលនយោបាយសង្គមនិងសេដ្ឋកិច្ចឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣0/២0៥0	គោលដៅទី ៤
១.១៧	លើកកម្ពស់វគ្គបណ្តុះបណ្តាលដែលមានភាពបត់បែនដោយផ្អែកលើម៉ូឌុលជាមួយវិញ្ញាបនបត្រ Micro / Nano	ចំនួនវគ្គបណ្តុះបណ្តាលផ្អែកលើម៉ូឌុលដែលត្រូវបានបង្កើតឡើងជាច្រើនសម្រាប់វិស័យ/ឧស្សាហកម្ម	ក្រោមគម្រោង TVETSDP ផ្អែកលើម៉ូឌុល និងសម្ភារសិក្សា និងការវាយតម្លៃកំពុងត្រូវបានបង្កើតឡើងសម្រាប់មុខរបរការថែទាំនិងជួស	សម្លៀកបំពាក់ និងវាយនភ័ណ្ឌ	វិស័យទេសចរណ៍ អាហារ និងភេសជ្ជៈ	ការជីករ៉ែ និងការរុករករ៉ែ	ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ.	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣0/២0៥0	គោលដៅទី ៤

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
			ជុលអគ្គិសនីរថយន្ត (ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ២) ការងារកំបោរ (ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ២) សេវាកម្មកុំព្យូទ័រ (ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ២)						
១.១៨	ការកំណត់ និងការអនុម័តបច្ចេកវិទ្យាថ្មីក្នុងគោលបំណងផ្តល់ការបណ្តុះបណ្តាលដោយមជ្ឈមណ្ឌលឧត្តមភាពតាមរយៈ	ចំនួនមជ្ឈមណ្ឌលបច្ចេកវិទ្យាកម្រិតខ្ពស់ដែលបាន	គ្មានព័ត៌មានគោល	១	១	១	ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ.	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥ ក្របខ័ណ្ឌគោលនយោបាយសង្គម និងសេដ្ឋកិច្ចឌីជីថល	គោលដៅទី ៤

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
	ការបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាកម្រិតខ្ពស់ (CAT)[1]	បង្កើតឡើង (តាមតំបន់)						កម្ពុជាឆ្នាំ២០២១-២០៣៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០/២០៥០	
១.១៩	ការអភិវឌ្ឍកម្មវិធី /ម៉ូឌុលសិក្សាលើជំនាញទន់ និងសម្ភារបណ្តុះបណ្តាល (រួមទាំងគោលការណ៍ណែនាំគ្រូឧទ្ទេស គោលការណ៍ណែនាំលើការវាយតម្លៃសមត្ថភាព) បន្ទាប់ពីស្តង់ដាសមត្ថភាពត្រូវបានផ្តល់សុពលភាពដោយឧស្សាហកម្ម	កម្មវិធី/ម៉ូឌុលសិក្សាត្រូវបានអភិវឌ្ឍសម្ភារបណ្តុះបណ្តាល	វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសបានអភិវឌ្ឍម៉ូឌុលចំនួន ៦ លើជំនាញទន់	៨	១០	១២	ការិយាល័យអភិវឌ្ឍន៍ជំនាញទន់នៃនាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា ដោយមានការគាំទ្រពីក្រុមប្រឹក្សាជំនាញតាមវិស័យ CAMFEBA	គោលនយោបាយជាតិ TVET ឆ្នាំ២០១៧-២០២៥ គោលនយោបាយជាតិមុខរបរ និងការងារ ឆ្នាំ ២០១៥-២០២៥ IDP ២០១៥-២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០/២០៥០	គោលដៅទី ៤

[1] វានឹងបម្រើជាមជ្ឈមណ្ឌលជំនាញមួយដែលនិស្សិតមកពីវគ្គសិក្សា/កម្មវិធីផ្សេងៗ នឹងប្រើការសិក្សាជាក់ស្តែងបែបនិម្មិត ៣D AI និងបច្ចេកវិទ្យាកម្រិតខ្ពស់ផ្សេងទៀតដើម្បី "ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ" ជំណើរការការងារ និងបរិស្ថាន។

ល.រ	សសរស្តម្ភ	សូចនាករនៃការអនុវត្ត	សូចនាករដើមគ្រា (២០២១)	គោលដៅប្រចាំឆ្នាំ			ក្រសួង/ ស្ថាប័នទទួលខុសត្រូវ	ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ	ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
				២០២២-២០២៥	២០២៦-២០៣០	២០៣០-២០៣៥			
១.២០	បញ្ចូលជំនាញទន់ទៅក្នុងកម្មវិធីសិក្សាសម្រាប់ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ៥ ឡើងទៅ	ភាគរយនៃជំនាញទន់ ដែលបានដាក់បញ្ចូលកម្មវិធី TVET	ម៉ូឌុលបណ្តុះបណ្តាលជំនាញទន់ត្រូវបានអភិវឌ្ឍ និងដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាសម្រាប់ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ១-៤	៣0%	៣0%	៤0%	ការិយាល័យអភិវឌ្ឍន៍ជំនាញទន់នៃនាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា ដោយមានការគាំទ្រពីក្រុមប្រឹក្សាជំនាញតាមវិស័យ	គោលនយោបាយជាតិ TVET ឆ្នាំ ២០១៧-២០២៥ គោលនយោបាយជាតិមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ IDP ២០១៥-២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣0/២0៥0	គោលដៅទី ៤
